អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក

ជាន់ទី១២ អាគារ Exchange Square
ផ្លូវលេខ១០៦ កែងផ្លូវលេខ៦១
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

AIA.COM.KH

# សេចក្តីប្រកាសសារព័ត៌មាន

## AIA បើកយុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីជំងឺមហារីកសុដន់ទូទាំងប្រទេស និងប្រមូលថវិកាជួយគាំទ្រ មន្ទីរពេទ្យព្រះសីហនុមណ្ឌលនៃក្តីសង្ឃឹម

**រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០២០** - ដើម្បីចូលរួមផ្សព្វផ្សាយការយល់ដឹង នៃជំងឺមហារីកសុដន់ ដែលតែងតែរៀបចំឡើងជារាងរាល់ឆ្នាំ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត AIA ប្រចាំនៅកម្ពុជា ចាប់ផ្តើមបើកយុទ្ធនាការផ្សព្វផ្សាយការយល់ដឹង និងការការពារខ្លួនពីជំងឺមហារីកសុដន់ ទទួលយកការពិនិត្យទាន់ពេលវេលា ( Fit for Hope ២០២០ ) នៅក្នុងខែតុលានេះ។

គោលបំណងនៃយុទ្ធនាការនេះ ដើម្បីបង្កើនការយល់ដឹងអោយកាន់តែទូលំទូលាយ ពីជំងឺមហារីកសុដន់ និងប្រមូលថវិកាសម្រាប់ជួយគាំទ្រ មន្ទីរពេទ្យព្រះសីហនុ មណ្ឌលនៃក្តីសង្ឃឹម ដែលជួយព្យាបាលអ្នកជំងឺមហារីកសុដន់ និងផ្តល់ការពិនិត្យដោយឥតគិតថ្លៃ ជាពិសេសលើកកម្ពស់ការយល់ ដឹងអំពីបញ្ហាដ៏ធ្ងន់ធ្ងរនេះ ទៅដល់ប្រជាជនកម្ពុជាទាំងស្ត្រី និងបុរស។

ក្រោមចក្ខុវិស័យដ៏មុតមាំរបស់ខ្លួន ក្នុងការជួយប្រជាជនកម្ពុជា ឲ្យមានសុខភាពល្អ និងជីវិតកាន់តែប្រសើរ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត AIA ប្រចាំនៅកម្ពុជា បន្តសហការជាមួយមន្ទីរពេទ្យព្រះសីហនុមណ្ឌលនៃក្តីសង្ឃឹម (Center of HOPE)ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺមហារីកសុដន់។ ថវិកាដែលប្រមូលបាននៅក្នុងយុទ្ធនាការនេះនឹងត្រូវប្រគល់ជូនជាផ្លូវការជូនមន្ទីរពេទ្យនៅពេលបញ្ចប់យុទ្ធនាការផ្សព្វផ្សាយក្នុងខែធ្នូ ២០២០។
នៅឆ្នាំនេះក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត AIA នឹងបង្កើនការយល់ដឹងអំពីយុទ្ធនាការ ដោយការផលិត និងដាក់ផ្សាយនូវវីដេអូអប់រំភាគ ដើម្បីជួយអប់រំដល់សាធារណជន ពីជំងឺមហារីកសុដន់នេះ។ កម្មវិធីនេះនឹងត្រូវបានគាំទ្រដោយកម្មវិធីហ្វេសប៊ុក ដែលនឹងបង្ហាញនៅលើដើមឈើនិម្មិតរូប តាមរយៈការចូលរួមគាំទ្ររបស់អ្នកនៅ ក្នុងយុទ្ធនាការនេះ ដោយការបន្ថែមបូពណ៌ផ្កាឈូក ដោយគ្រាន់តែចូលលេង និងចែករំលែកដល់មិត្តភ័ក្តិរបស់អ្នក ឲ្យបានដឹងនិងចូលរួមជាមួយនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមហ្វេសប៊ុកនេះ។

ក្នុងឆ្នាំ២០១៨ យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីជំងឺមហារីកសុដន់ ទទួលបានការគាំទ្ររាប់ម៉ឺននាក់ ដោយការរៀបចំសកម្មភាពផ្សព្វផ្សាយជាច្រើនដូចជា ផ្សព្វផ្សាយសម្រាប់បុគ្គលិក និងសហការី តារាល្បីៗ ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកមានឥទ្ធិពល រៀបចំសិក្ខាសាលាដល់និស្សិតនៅតាមសាកលវិទ្យាល័យ និងសកម្មភាពផ្សព្វផ្សាយនៅតាមទីផ្សារ ហើយផ្តល់ការពិនិត្យជំងឺមហារីកសុដន់ដោយឥតគិតថ្លៃរហូតដល់១៣០០ នាក់ ការដើរព្យុហយាត្រា Pink Walk ដែល

មានអ្នកចូលរួម ២០០០នាក់ និងជួបជុំនៅកោះពេជ្រ រួមជាមួយវគ្គបណ្តុះបណ្តាល Zumba ដែលមានអ្នកចូលរួមប្រមាណ ៨០០នាក់។

កម្មវិធីជាបន្តបន្ទាប់ ត្រូវបានបញ្ចប់ជាមួយនឹងការប្រគំតន្ត្រីមួយដ៏ធំ ដែលមិនអាចបំភ្លេចបាន រួមជាមួយការផ្ញើសារលើកទឹកចិត្ត ដល់អ្នកគ្រប់គ្នាឲ្យរស់នៅចេះបង្ការខ្លួន និងចៀសឆ្ងាយពីជំងឺមហារីកសុដន់ ដែលមានការចូលរួមពីតារាល្បីៗប្រចាំប្រទេសកម្ពុជា និងអ្នកគាំទ្រប្រមាណ ២០,០០០ នាក់។

អ្នកទាំងអស់គ្នាអាចចូលរួម ដោយបរិច្ចាគដល់មូលនិធិនៃយុទ្ធនាការផ្សព្វផ្សាយ ការយល់ដឹងនៃកាការពារខ្លួនពីជំងឺមហារីកសុដន់ សម្រាប់ឆ្នាំ២០២០ ដែលនឹងត្រូវប្រគល់ជូនមន្ទីរពេទ្យ HOPE នៅពេលបញ្ចប់យុទ្ធនាការ។ ផ្តើមចេញពីខ្លួនអ្នក សូមទៅទទួលយកពិនិត្យ និងចែករំលែកការយល់ដឹងនេះ ដោយចាប់ផ្តើមនិយាយ ពីជំងឺមហារីកសុដន់ទៅកាន់មិត្តភិក្តិ និងក្រុមគ្រួសារ។ ការចូលរួមបរិច្ចាគប្រាក់ ៥ដុល្លាររបស់អ្នក នឹងទទួលបានជាអាវយឺតដ៏ស្រស់ស្អាតមួយ ដើម្បីជាការថ្លែងអំណរគុណនូវទឹកចិត្តថ្លៃថ្លារបស់អ្នក ដោយអ្នកអាចផ្ញើប្រាក់បរិច្ចាគរបស់អ្នក មកកាន់មូលនិធិនៃយុទ្ធនាការផ្សព្វផ្សាយ ការយល់ដឹងនៃការការពារខ្លួនពីជំងឺមហារីកសុដន់ ជាផ្លូវការ តាមរយៈគណនីធនាគារ ABA 001052306 បន្ទាប់មកអ្នកចុច screenshot នូវប្រតិបត្តិការផ្ញើប្រាក់បរិច្ចាគរបស់អ្នក រួចផ្ញើសារមកកាន់ Facebook Messenger នៃ Facebook Page របស់ AIA Cambodia ដើម្បីបញ្ជាក់ជាការស្រេច។ ក្រុមការងារ AIA នឹងទាក់ទងលោកអ្នកវិញ ដើម្បីប្រគល់ជូនអាវយឺតដ៏ស្រស់ស្អាតជូនអ្នក នៅគ្រប់ខេត្តក្រុងទូទាំងប្រទេស។

ប្រសិនបើលោកអ្នកនៅមានចម្ងល់ ឬសាកសួរព័ត៌មានបន្ថែម សូមទូរស័ព្ទមកកាន់លេខ 098 980 757 ។ យើងខ្ញុំមានមោទនភាពបំផុត ចំពោះលោកអ្នកដែលអាចចូលរួមបរិច្ចាគថវិកាច្រើនៗលើសពី៥$ តាមលទ្ធភាពបរិច្ចាគរបស់អ្នក។ ថវិកាទាំងអស់នឹងជួយគាំទ្រដល់មូលនិធិនៃយុទ្ធនាការ ដែលនឹងជួយដល់ស្ត្រីខ្មែរដែលត្រូវជំនួយ ដើម្បីទទួលបានការពិនិត្យ និងការព្យាបាលជំងឺមហារីកសុដន់នេះទាន់ពេលវេលា៕

*អេ អាយ អេ ខេមបូឌា ធ្វើឲ្យជីវិតយុវជនខ្មែរកាន់តែប្រសើរឡើង តាមរយៈការពង្រីកការគាំទ្រក្រុមកីឡាយុវជនដែលធំជាងគេ បង្អស់ទំព័រទី ៣*

## អំពីអេអាយអេខេមបូឌា

អេអាយអេគ្រុប លីមីតធីត និង សាខា (តទៅហៅថា អេអាយអេ "AIA" ឬ គ្រុប "Group") មានក្រុមហ៊ុនធានារ៉ាប់រងជីវិតនៅទូទាំងតំបន់អាស៊ីដែលស្ថិតក្នុងបញ្ជីឈ្មោះសាធារណៈឯករាជ្យធំជាងគេ ។ ក្រុមហ៊ុនមានវត្តមាននៅលើទីផ្សារចំនួន ១៨ ប្រទេសនៅអាស៊ីប៉ាស៊ីហ្វិក - សាខាគ្រប់គ្រងទាំងស្រុង និង ក្រុមហ៊ុនបុត្រសម្ព័ន្ធនៅទីក្រុងហុងកុង SAR ប្រទេសថៃ សឹង្ហបូរី ម៉ាឡេស៊ី ចិនដីគោក កូរ៉េខាងត្បូង ហ្វីលីពិន អូស្ត្រាលី ឥណ្ឌូនេស៊ី (ចិន) តៃវ៉ាន់ វៀតណាម ញ៉ូហ្ស៊ីលែន ម៉ាកាវ SAR ប្រ៊ុយណេ កម្ពុជា មីយ៉ាន់ម៉ា ក្រុមហ៊ុនបុត្រសម្ព័ន្ធដែល ៩៩ ភាគរយនៅប្រទេសស្រីលង្កា និង ក្រុមហ៊ុនបណ្តាក់ទុនរួម ៤៩ ភាគរយនៅប្រទេសឥណ្ឌា។

ក្នុងពេលបច្ចុប្បន្ន អាជីវកម្មរបស់ក្រុមហ៊ុន គឺដូចគ្នានិង អេអាយអេ ដែលត្រូវបានបង្កើតឡើងលើកដំបូងនៅទីក្រុងសៀងហៃ កាលពីមួយសតវត្សកន្លងទៅក្នុងឆ្នាំ ១៩១៩ ។ ជាក្រុមហ៊ុនឈានមុខគេមួយនៅលើទីផ្សារ ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក (អតីត-ជប៉ុន) ដោយផ្តោតទៅលើបុព្វលាភធានារ៉ាប់រងជីវិត និង មានតួនាទីនាំមុខគេនៅគ្រប់ទីផ្សារភាគច្រើនរបស់ខ្លួន ។ ក្រុមហ៊ុនមានទ្រព្យសម្បត្តិសរុបចំនួន ២៨៤ ពាន់លានដុល្លារអាមេរិក ចាប់តាំងពីឆ្នាំ ២០១៩។

អេអាយអេ ឆ្លើយតបតាមតម្រូវការនៃប្រាក់សន្សំ និង ការការពាររយៈពេលវែងរបស់ ពលរដ្ឋទូទៅតាមរយៈការផ្តល់នូវផលិតផលដ៏សម្បូរបែប និង សេវាកម្មជាច្រើនរួមមាន ការធានារ៉ាប់រងជីវិត គ្រោះថ្នាក់ ការធានារ៉ាប់រងសុខភាព និង ផែនការសន្សំប្រាក់ ។ ក្រុមហ៊ុនគ្រុប ក៏ផ្តល់ផងដែរនូវប្រាក់អត្ថប្រយោជន៍សម្រាប់បុគ្គលិក ផ្តល់ឥណទានអាយុជីវិត និង សេវាកម្មប្រាក់សោធនិវត្តន៍ ។ តាមរយៈបណ្តាញភ្នាក់ងារ ដៃគូ និង បុគ្គលិកដ៏ទូលំទូលាយនៅទូទាំងតំបន់អាស៊ីប៉ាស៊ីហ្វិក អេអាយអេ បានផ្តល់ដល់ម្ចាស់ប័ណ្ណធានានូវ ប័ណ្ណធានារ៉ាប់រងរូបវន្តបុគ្គលច្រើនជាង ៣៦ លាននាក់ និង សមាជិកដែលបានចូលរួម ផែនការធានារ៉ាប់រងជាក្រុមជាង ១៦ លាន នាក់។

អេអាយអេគ្រុបលីមីតធិត (AIA Group Limited) ត្រូវបានដាក់បញ្ចូលក្នុង តារាងនៃក្រុមប្រឹក្សាភិបាលចម្បងនៃ គណកម្មាធិការផ្សារមូលបត្រទីក្រុងហុងកុង (Main Board of The Stock Exchange of Hong Kong Limited) ដែលស្ថិតក្រោមច្បាប់ផ្សារមូលបត្រ "១២៩៩" ស្របតាមច្បាប់ស្តីពី ការទទួលប្រាក់តម្កល់នៃសហរដ្ឋអាមេរិក (កម្រិត ១) A=(American Depositary Receipts (Level 1) ដែលធ្វើពាណិជ្ជកម្មលើទីផ្សារស្របច្បាប់ (រូបសញ្ញា: "AAGIY")។

**ទំនាក់ទំនងសារព័ត៌មាន**

ម៉េង ដាណែត
ប្រធានផ្នែកទីផ្សារ និងទំនាក់ទំនង
អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក
Daneth-d.Meng@aia.com